N"07_A4_5.qxd 06/16/2006 10:18 Morning Page I

# ព្រាបសន្តិភាព

មិថុនា ២០០៥



តើមានចំណុចអ្វីខ្លះដើម្បីអោយខ្ញុំក្លាយទៅជាកូនល្អ?

PHOTOS: Kike FIGAREDO



កូនល្អ ទំព័រ ១



សែម សំអាង ទំព័រ ៣



សុខ លើម អតីតយុទ្ធជន ទំព័រ៦
កំណាព្យ ទំព័រ៤
កុមារនិងអំពើហិង្សា ទំព័រ៨

N"07_A4_5.qxd 06/16/2006 10:18 Morning Page II

# តើខ្ញុំត្រូវធ្វើដូចម្តេចទើបក្លាយទៅជាកូនល្អ?



PHOTOS: Kike FIGAREDO

ត្រូវចេះស្តាប់បង្គាប់ឪពុកម្តាយ

ខិតខំរៀនសូត្រ

ឆ្លៀតធ្វើកិច្ចការផ្ទះ

ចេះគោរពចាស់ទុំ

ធ្វើចិត្តសុភាពទន់ភ្លន់

ការចេះអត់ឱន

កូនល្អ!!! ពាក្យនេះគឺជាពាក្យដ៏ល្អ និងពីរោះស្តាប់ណាស់។ កុមារគ្រប់ៗរូបតែងតែចង់អោយអ្នកដទៃជាពិសេសឪពុកម្តាយរបស់ខ្លួនអួតសរសើរថាខ្លួនជាកូនល្អ។ ឪពុកម្តាយគ្រប់ៗរូបក៏ដូចនេះដែរគឺគាត់តែងតែចង់អោយបុត្រធីតារបស់ខ្លួនមានឈ្មោះថាជាបុត្រដ៏ល្អជានិច្ច។ ចុះចំណែកប្អូនៗវិញតើប្អូនៗចង់ក្លាយទៅជាកូនល្អរឺទេ? បើប្អូនៗចង់ក្លាយទៅជាកូនល្អនោះវាជាការងាយស្រួលទេហើយប្អូនៗក៏ប្រហែលជាធ្លាប់ដឹងខ្លះៗដែរតាមរយៈឪពុកម្តាយបងប្អូននិងលោកគ្រូអ្នកគ្រូរបស់ប្អូនៗនោះថាតើប្អូនៗត្រូវធ្វើយ៉ាងណាខ្លះទើបក្លាយទៅជាកូនល្អម្នាក់? ដើម្បីក្លាយទៅជាកូនល្អប្អូនត្រូវចេះផ្គាប់ចិត្តអ្នកដែលនៅជុំវិញប្អូនជានិច្ចដែលមានដូចជា ឪពុកម្តាយ ចាស់ទុំ អ្នកជិតខាង រឺមិត្តភិក្តិប្អូនជាដើម។ អ្នកទាំងនេះតែងតែចាំសង្កេតមើលនូវរាល់សកម្មភាពរបស់ប្អូនជានិច្ច ។ដូចនេះតើប្អូនត្រូវផ្គាប់ចិត្តយ៉ាងណាទើបអាចអោយគេស្រលាញ់និងចាត់ទុកប្អូនជាកូនល្អនោះ?ខាងក្រោមនេះគឺជាចំណុចសង្ខេបៗដែលកូនល្អត្រូវមាន រឺក៏កូនល្អអាចអនុវត្តតាមហើយប្អូនក៏ត្រូវប្រកាន់នូវទំលាប់ដ៏ល្អនៅក្នុងការអនុវត្តន៏នោះដែរ។ ពេលយូរៗទៅប្អូននឹងធ្លាប់ដោយឯងៗជាមិនខាន។

កូនល្អត្រូវចេះស្តាប់បង្គាប់ឪពុកម្តាយជាពិសេសគឺចេះស្តាប់ដំបូន្មានរបស់ពួកគាត់។ គោរពដំបូន្មានឪពុកម្តាយគឺរមែងបាននូវសេចក្តីសុខ។ កូនល្អត្រូវចេះខិតខំរៀនសូត្រមិនចាំបាច់អោយឪពុកម្តាយដាស់តឿនរឺរំលឹកញឹកញាប់ពេកនោះទេហើយក៏មិនដែលធ្វើអោយពួកគាត់មានការព្រួយបារម្ភ រឺខឹងសម្បានោះដែរ។

ភាពខ្ជិលច្រអូស មិនមែនជាកូនល្អនោះទេកូនល្អគឺតែងតែជួយឆ្លៀតធ្វើកិច្ចការផ្ទះជានិច្ចមិនមានការត្អូញត្អែរនោះឡើយ។ កូនដែលមិនចេះគោរពចាស់ទុំ ប្រើពាក្យសំដីព្រហើនកោងកាចនោះរិតតែលែងជាកូនល្អទៀតហើយ ។ចូរប្អូនធ្វើចិត្តសុភាពទន់ភ្លន់ជាងធ្វើរឹងរូសកោងកាច ។ ការដឹងគុណការចេះគោរពចាស់ទុំនិងការចេះអត់អោនអោយគ្នាទៅវិញទៅមកគឺជាចំណុចដែលកូនល្អត្រូវមានជានិច្ច។ មនុស្សម្នាក់ៗគឺតែងតែមានកំហុសជានិច្ចតែចំពោះកូនល្អវិញពេលដែលធ្វើខុសម្តងហើយគឺចងចាំទុកក្នុងចិត្តជានិច្ចហើយក៏មិនដែលអោយកំហុសដដែលនោះកើតមានម្តងទៀតដែរ។ ពេលទៅណាមកណាកូនល្អតែងតែសុំការអនុញ្ញាតពីឪពុកម្តាយជានិច្ចមិនដែលភូតកុហករឺគេចវេះនោះឡើយ។ ការកំណាញ់លោភលន់ការឈ្នានីសអ្នកដទៃញុះញង់បំបែកបំបាក់អ្នកដទៃរឺលួចទ្រព្យសម្បត្តិអ្នកដទៃគឺតែងតែនាំមកនូវក្តីអន្តរាយនោះមិនមែនជាកូនល្អទេហើយថែមទាំងមានឈ្មោះថាជាកុមារ *តទៅទំព័រ៤*

N”07_A4_5.qxd 06/16/2006 10:18 Morning Page III

# សំ អាង: ជោគជ័យក្នុងជីវិត ស្ថិតលើការព្យាយាម និងជឿជាក់



PHOTOS: Sophal

ដើម្បីសំរេចបំណងគឺត្រូវមាន
កត្តាខាងក្រោមនេះ

១-គ្រួសារ

២-សង្គមបរិយាកាសខាងក្រៅ

៣-សាលារៀន

៤-មិត្តភក្តិ

៥-ខ្លួនឯងផ្ទាល់

*"ជោគជ័យនៃជីវិត ស្ថិតលើការព្យាយាម និងជឿជាក់"*

ពិធីចែករង្វាន់ដល់សិស្សពូកែទទួលជ័យលាភីថ្នាក់ប្រទេស និងថ្នាក់ខេត្តបានរៀបចំឡើងនៅបរិវេណ វិទ្យាល័យ ហ៊ុនសែន អង្គស្នួល នាថ្ងៃអង្គារ ទី ៣១ ឧសភា ឆ្នាំ ២០០៥ ដែលមានលោកគ្រូអ្នកគ្រូសិស្សានុសិស្សមកពីអនុវិទ្យាល័យបែកចាន រួមជាមួយលោកគ្រូ អ្នកគ្រូ សិស្សានុសិស្សវិទ្យាល័យហ៊ុនសែន អង្គស្នួល សរុបទាំងអស់ប្រមាណជិត ៣ពាន់នាក់ ។ គណៈអធិបតីអញ្ជើញជាកិត្តិយសក្នុងឱកាសនោះមាន លោក អ៊ុន យ៉ុន និងលោក ឈុន សុភាព ជាអភិបាលរង ស្រុកអង្គស្នួល, លោក ប៉ែន សេដ្ឋា ជាប្រធានការិយាល័យអប់រំ ស្រុកអង្គស្នួល ព្រមទាំងភ្ញៀវកិត្តិយសជាច្រើនរូបទៀត មានជាអាទិ៍: លោក ឡុង សុផល តំណាងអង្គការ JS លោក ញ៉ឹប លី នាយកអនុវិទ្យាល័យបែកចាន,លោក ឡឹក សំ អាង នាយក អនុវិទ្យាល័យ ទួលស្មោរ និងអស់លោក លោកស្រីជាច្រើនរូបទៀតដែលអញ្ជើញមក ពីបណ្តាអនុវិទ្យាល័យ, សាលាបឋមសិក្សា, មាតាបិតាសិស្ស និងមន្ត្រីអាជ្ញាធរទាំងអស់ប្រចាំ ស្រុកអង្គស្នួល ខេត្តកណ្តាល។

លោក ហង់ ឈុំ នាយកវិទ្យាល័យ ហ៊ុន សែន អង្គស្នួល មានប្រសាសន៍ថាការរៀបចំពិធីនេះឡើងក្នុងគោលបំណងលើកទឹកចិត្តដល់យុវសិស្ស ជាសិស្សពូកែទទួលជ័យលាភីចំណាត់ថ្នាក់លេខ១ ប្រចាំខេត្ត កណ្តាល និងចំណាត់ថ្នាក់លេខ ១ ទូទាំងប្រទេសលើមុខវិជ្ជាភាសាខ្មែរថ្នាក់ទី ១២ និងសិស្ស ពូកែចំនួន ៣ នាក់ទៀតដែលបានខិតខំប្រឹងប្រែងសិក្សាស្រាវជ្រាវរហូតដណ្តើមបាននូវកិត្តិយសដ៏ថ្លៃថ្លា ជូនដល់សាលា ក៏ដូចជាដល់ស្រុកអង្គស្នួល ដែលជាស្រុកកំណើតរបស់ខ្លួនដែរ ។ លោកនាយក បានបញ្ជាក់ថា នៅក្នុងស្រុកអង្គស្នួលមានអង្គការ JS បានជួយគាំទ្រយ៉ាងខ្លាំង ឧបត្ថម្ភជាអំណោយដល់វិទ្យាល័យ រួមចំណែកយ៉ាងធំធេងក្នុងការអភិវឌ្ឍន៍ធនធានមនុស្ស នៅកម្ពុជា ប្រកបដោយ គុណភាព ។

មកដល់បច្ចុប្បន្នសាលាទទួលបានពីអង្គការនូវបណ្ណាល័យ **ព្រាបស** សំរាប់ស្រាវជ្រាវ ១ខ្នង, របងថ្ម ប្រវែង ៤៥៣ម, បង្គន់អនាម័យ ៤ខ្នងមាន៨បន្ទប់, ម៉ាស៊ីនកុំព្យូទ័រ ១គ្រឿង...។ល។ បន្ថែមពីលើនេះអង្គការបាននិងកំពុងបន្តឧបត្ថម្ភនូវសៀវភៅឯកសារ, ទស្សនាវដ្តី, សារព័ត៌មានផ្សេងៗ ជាច្រើនទៀតសំរាប់ជាប្រយោជន៍ដល់លោកគ្រូអ្នកគ្រូ,សិស្សានុសិស្សចូលអានស្រាវជ្រាវក្នុងបណ្ណាល័យដើម្បីពង្រីកចំណេះដឹងបង្កើនសមត្ថភាពអោយកាន់តែប្រសើរឡើង ។ នាឱកាសនោះអំណោយជាសៀវភៅ និងសម្ភារៈផ្សេងៗ ដែលបានមកពីការឧបត្ថម្ភពីសប្បុរសជននានា អង្គការក្រៅរដ្ឋាភិបាល..... ត្រូវបានប្រគល់ជូនដល់សិស្សពូកែទាំង ៤ រូប និងលោកគ្រូដែលមានស្នាដៃ ល្អមួយចំនួនទៀត។

មានមតិសំណេះសំណាលក្នុងពិធីដ៏ឧឡារិកនោះលោក អ៊ុន យ៉ុន អភិបាលរងស្រុក អង្គស្នួល បានបញ្ជាក់លើកឡើងពីការបានខិតខំប្រឹងប្រែងរៀនសូត្ររបស់ក្មួយៗ *តទៅទំព័រ៦*

N"07_A4_5.qxd 06/16/2006 10:18 Morning Page IV

# សួនកំណាព្យ

បទពាក្យ៧

ភាគទី៦

## គុណម្តាយ

និពន្ធ អ្នកស្រី ខុង ណារី

កូនល្អម៉ែសុខក្រៃកន្លង    នេះជាបំណងដែលជីដូន
អោយម៉ែគ្រប់គ្រងរក្សាកូន    ខ្លាចក្រែងមាសស្ងួនក្តៅរងា ។
ពេលកូនបានសុខម៉ែសុខផង    ពេលកូនមានហ្មងម៉ែពុំជា
កូនតូចកែវទិព្វពេជ្រពណ្ណរាយ    ឋានសុខសួគាប្រទានអោយ ។
កូនជាដួងចិត្តជីវិតម៉ែ    កូនពេជ្រមាសស្នេហ៍ជាអំណោយ
ទេវតាលោកបានប្រទានអោយ    កែវពេជ្រនេះហើយកូនពាលពៅ ។
ម្តាយបីរូបកូនពេញហត្ថា    អោយស្រស់ជីវ៉ាកូននាងបៅ
បំពេរបុត្រតូចអោយគេងទៅ    ម្តាយលើកពីភ្លៅដាក់អង្រឹង ។
ម្តាយយោលអង្រឹងជាប់ជានិច្ច    មិនហ៊ានទម្ងិចស្ងៀមស្ងាត់ឈឹង
ខ្លាចប៉ះកូនភ្ញាក់លោះព្រលឹង    ម្តាយស្ងៀមនៅនឹងយោលពិសី ។
ម្តាយឆ្លៀតយោលផងធ្វើការផង    សំឡឹងកូនផងគិតមមៃ
ឃើញវង់ភ័ក្រ្តកូនស្រស់ប្រឹមប្រិយ    ធំឡើងដឹងក្តីឆ្លាតណាកូន ។
កូនធំបន្តិចបែបរាងរឹង    កូនខ្លាំងទទឹងអាងជីដូន
ម៉ែខឹងអន់ចិត្តមុខស្រពោន    វាយកូនរួចគិតអាណិតក្រោយ ។
ម៉ែខ្លាចកូនធំខូចខិលកាច    ដូច្នេះម៉ែខ្លាចមិនបណ្តោយ
កុំអោយសៅហ្មងទៅថ្ងៃក្រោយ    អប់រំអោយហើយទាន់នៅខ្ចី ។
កូនមានអាយុបានប្រាំឆ្នាំ    ម្តាយរៀបចំចាំដាក់មត្តេយ្យ
អោយកូនស្គាល់មិត្តភ័ក្រ្តប្រុសស្រី    រៀននិយាយស្តីបានគួរសម ។
ពេលកូនឃ្លាតឆ្ងាយម្តាយនឹកគិត    ដួងចិត្តភ័យភិតគិតបារម្ភ
ខ្លាចកូនកើតខ្យល់ខ្វល់រឿងធំ    ម្តាយព្រួយបារម្ភគ្រប់វេលា ។
ពេលឃើញរូបកូនមកដល់ផ្ទះ    ម៉ែសប្បាយណាស់ព្រោះកូនជា
គ្មានអ្វីអរជាងឃើញបុត្រា    រូបស្រស់សោភាមានសុខា ។
កូនបានចូលរៀនថ្នាក់ទីមួយ    លោកគ្រូគាត់ជួយប្តូរសាលា
ម្តាយផ្តាំអោយកូនខំសិក្សា    ដើម្បីតម្រាតំរេះខ្លួន ។
កូនអើយឆ្នាំចាស់កន្លងទៅ    ឆ្នាំថ្មីប្តូរនៅជាប់ៗ ជួន
ថ្ងៃខែចេះតែប្តូរផ្លូនៗ    ហូរហែសមស្ងួនកូនរីកវ័យ ។
កូនត្រូវខំរៀនណាកូនណា    ត្រូវខំសិក្សាទាន់នៅខ្ចី
វិជ្ជាជាទ្រព្យដ៏ប្រពៃ    កេរ្តិ៍ម៉ែដ៏ថ្លៃចែកអោយកូន ។
វិជ្ជាជាទ្រព្យថ្លៃជាងមាស    ទោះកូនគ្រវាសអោយបាត់សូន្យ
ឬចោរប៉ុនប៉ងប្លន់ពីកូន    មិនបានឡើយស្ងួនទួនចរណៃ ។



# តើខ្ញុំត្រូវធ្វើដូចម្តេច...?

ដ៏អាក្រក់ទៀតផង។ កូនល្អពេលធ្វើខុសគឺតែងតែទទួលកំហុសហើយក៏មិនដែលចាប់កំហុសរឺទំលាក់កំហុសអោយអ្នកដទៃដែរ។ កូនល្អគឺជាមនុស្សដែលមានអនាមយ័ជានិច្ចមិនធ្វើអោយឪពុកម្តាយបារម្ភពីសុខភាពរបស់ខ្លួននោះឡើយ។ កូនល្អតែងតែជៀសផុតពីការប្រើប្រាស់គ្រឿងញៀនរឺគ្រឿងស្រវឹងផ្សេងៗដែលសង្គមស្អប់ខ្ពើមបំផុតនោះ។

មិត្តសំលាញ់របស់កូនល្អគឺសុទ្ធតែជាមនុស្សល្អហើយក៏មានចំណុចសំខាន់ៗខាងលើនេះនៅក្នុងខ្លួនដែរ។

កូនល្អចេះស្រលាញ់បងប្អូនមិនដែលឈ្លោះប្រកែករឺទាស់ទែងគ្នាដោយប្រការណាមួយនោះឡើយ។ ដូចនេះបើប្អូនៗអាចអនុវត្តន៏បាននោះប្អូនៗក៏មិនមែនបានត្រឹមតែជាកូនល្អនោះទេគឺប្អូនអាចឈានទៅដល់សិស្សល្អមិត្តល្អនិងជាពលរដ្ឋដ៏ល្អមួយរូបទៀតហើយពិតជាសក្តិសមជាកុលបុត្រកុលធីតាអង្គរនៃព្រះរាជាណាចក្រកម្ពុជាយើងនិងជាទំពាំងស្នងឫស្សីដ៏ពិតប្រាកដរបស់ប្រទេសជាតិនិងអាចក្លាយខ្លួនទៅជាសមាជិកដ៏មានប្រយោជន៏ម្នាក់នៅក្នុងសង្គម។ បងសង្ឃឹមទុកជាមុនថាប្អូនៗនឹងបានសំរេចបំណងរបស់ប្អូននិងប្អូនអាចឈានទៅដល់គោលដៅដែលប្អូនចង់បានក្នុងគុណប្រយោជន៏សំរាប់ខ្លួនផងនិងសំរាប់សង្គមផងទៅថ្ងៃអនាគត ៕

*ដោយ ក.សៀប*

# សុខលីម "ខ្ញុំត្រូវតែតស៊ូរស់ដើម្បីក្រុមគ្រួសារខ្ញុំនិងអនាគតកូន"

សុខ លីម អាយុ៣៨ឆ្នាំ

"ខ្ញុំសូមផ្តាំផ្ញើដល់បងប្អូនពិការទាំងអស់ថា ត្រូវចេះតស៊ូក្នុងជីវិតរបស់យើងម្នាក់ៗ ។ ត្រូវរកអាជីពអ្វីមួយដែលពិត-ប្រាកដសំរាប់ខ្លួនយើង"



PHOTOS: Sok eng

ភូមិភាគពាយ័ព្យជាប់ព្រំដែនថៃនូវមានបន្សល់ទុកនៅគ្រាប់មីននិងអ្នកពិការជាច្រើនក្រោយពីសង្គ្រាមបានផុតរលត់ទៅជាច្រើនឆ្នាំមកហើយនោះ ។ ប៉ុន្តែ " ជីវិតគឺជាការតស៊ូ " នេះជាសំដីរបស់អ្នកពិការម្នាក់ ឈ្មោះ សុខ លីម ដែលបច្ចុប្បន្នជាជាងឈើដ៏ចំណានម្នាក់ និង ជាទីស្រឡាញ់រាប់អានពេញនិយមរបស់អ្នកភូមិករសិន ឃុំថ្មពួក ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ចំពោះស្នាដៃផលិតតុ ទូ ធ្វើពីឈើសាមញ្ញ និងមានតំលៃសមរម្យ ។

គាត់បានរៀបរាប់ដោយទឹកមុខញញឹម ទន្ទឹមនឹងដៃរបស់គាត់ឈូសឈើដោយមានប្រពន្ធគាត់អង្គុយលក់ចាប់ហួយក្បែរនោះពីខ្សែជីវិតគាត់ចាប់តាំងពីធ្លាក់ខ្លួន ពិការរហូតមកដល់បច្ចុប្បន្ននេះមានដូចតទៅ :" បច្ចុប្បន្នខ្ញុំមានប្រពន្ធ និង កូនពីរនាក់ ស្រីម្នាក់ ប្រុស ម្នាក់ ហើយនិងម្តាយម្នាក់ក្នុងបន្ទុក ។ កាលពីឆ្នាំ ១៩៨៨ ខ្ញុំត្រូវបានកងទ័ពប៉ារ៉ាកេណ្ឌអោយទៅជញ្ជូនគ្រាប់ទៅប្រយុទ្ធនៅភ្នំដងរែកត្រង់ព្រំប្រទល់ខ្មែរថៃ ខ្ញុំត្រូវតែ ធ្វើតាមគេ ។ ក្រោយមកនាយទាហានប៉ារ៉ាក៏បំពាក់អាវុធអោយខ្ញុំធ្វើជាទាហានតែម្តងទៅទោះបីជាខ្ញុំប្រកែកយ៉ាងណាក៏មិនបានសំរេចដោយពួកគេបោះទីតាំងនៅអូរស្មាច់ ។ ខ្ញុំតែងតែនឹកគិតទៅដល់ក្រុមគ្រួសាររបស់ខ្ញុំដែលរស់នៅក្នុងភូមិមិនដឹងជាសុខទុក្ខយ៉ាងណានោះ ជាពិសេសម្តាយខ្ញុំគាត់ទីពឹងលើខ្ញុំទាំងស្រុងដែលជាកូនប្រុសក្នុងគ្រួសារ ។ ធ្វើទាហានខ្ញុំមានការលំបាកក្នុងជីវភាពជាខ្លាំងដោយប្រាក់ខែតិចតួចត្រូវបែងចែកមកអោយប្រពន្ធកូនផងនិងទុកចាយខ្លួនឯងផងសំខាន់បំផុតនោះគឺខ្លួនត្រូវឃ្លាតឆ្ងាយពីប្រពន្ធកូនជាទីស្រឡាញ់ថែមទៀតគិតទៅវាកំសត់ខ្លាំងណាស់ ។ ក្រោយមកនៅឆ្នាំ១៩៩៦កងទ័ពរដ្ឋា-ភិបាលនិងកងទ័ពប៉ារ៉ាក៏ត្រូវបានបញ្ចូលគ្នាជាទ័ពតែមួយ ។

ព្រឹកថ្ងៃមួយ ក្រុមខ្ញុំបានទទួលបញ្ជាអោយដើរល្បាតឃ្លាំមើលសត្រូវគឺខ្មែរក្រហមនៅភូមិជ្រោយប្រស់ឃុំជ្រោយប្រស់ទីរួមខេត្តកោះកុង ។ ខ្ញុំពុំបានដឹងថាតំបន់នោះមានមីនទេ ។ ពេលដើរល្បាតជើងស្តាំរបស់ខ្ញុំបានជាន់លើមីន ហើយក៏ផ្ទុះដាច់ជើងភ្លាមមួយរំពេចខ្ញុំប្រឹងស្រាយកន្សែងពីខ្លួនមកចងដើម្បីឃាត់ឈាមហើយក៏បាញ់កាំភ្លើងបីគ្រាប់ឡើងលើជាសញ្ញាអោយទាហានឯទៀតមកជួយសង្គ្រោះ ។ ទាហានដែលនៅក្នុងជួរទ័ពជាមួយបានមកសែងខ្ញុំបញ្ជូនទៅមន្ទីរពេទ្យដងទង់ក្នុងទីរួមខេត្តកោះកុងជាបន្ទាន់ ព្រឹកថ្ងៃបន្ទាប់ទើបដឹកខ្ញុំតាមយន្តហោះមកសំរាកព្យាបាលរយៈពេលមួយឆ្នាំនៅមន្ទីរពេទ្យព្រះកេតុមាលា( ពេទ្យ៧មករា) ចាប់តាំងពីពេលនោះមកខ្ញុំក៏ធ្លាក់ខ្លួនជាជនពិការម្នាក់ ។

ក្នុងពេលសំរាកព្យាបាលក្នុងមន្ទីរពេទ្យ ខ្ញុំបានគិតក្នុងចិត្តថាការធ្វើសង្គ្រាមចៀសមិនផុតពីគ្រោះថ្នាក់ទេ ហើយមានមនុស្សជាច្រើននាក់ដែលធ្លាក់ខ្លួនពិការដូចរូបខ្ញុំ ។

ដូច្នេះខ្ញុំត្រូវតែតស៊ូរស់ដើម្បីក្រុមគ្រួសារខ្ញុំនិងអនាគតកូន ទោះបីជាធ្លាក់ខ្លួនពិការក៏ដោយខ្ញុំត្រូវតែតស៊ូរស់នៅតទៅទៀត ទោះយ៉ាងណាក៏គ្រាន់ បានឃើញមុខប្រពន្ធ និង កូនដែរ ។

ក្រោយពីជាសះស្បើយខ្ញុំបានវិលត្រលប់មកភូមិវិញដោយទទួលបាននូវប្រាក់គោលនយោបាយចំនួន ៩៥000 រៀល ( ប្រាំបួនម៉ឺនប្រាំពាន់រៀល) ក្នុងមួយខែ ។ ក្រោយមកនៅ *តទៅទំព័រ៦*

N″07_A4_5.qxd 06/16/2006 10:18 Morning Page VI

# ជោគជ័យក្នុងជីវិត...

រហូតសំរេចបានជោគជ័យក្នុងការប្រឡងលើកកិត្តិយសដ៏ថ្លៃថ្លាអោយសាលាដូចជាយុវសិស្ស សែម សំ អាង ដែលជាកូនកសិករពិតៗនៅជនបទអាចដណ្តើមបានជ័យលាភីចំណាត់ថ្នាក់លេខ១ ប្រចាំខេត្តកណ្តាលហើយអាចទទួលចំណាត់ថ្នាក់លេខ១ទូទាំងប្រទេសទៀតនេះជាប្រការគួរអោយសរសើរនិងជាគំរូដល់ក្មួយៗជំនាន់ក្រោយទៀត។ លោកបានមានមតិបន្ថែមទៀតដល់អ្នកសិក្សាទាំងឡាយថា គំនិតគួរចងចាំតាមការស្រាវជ្រាវមួយបាន បញ្ជាក់ថា " បើមិនធ្វើលំហាត់ទេ យើងនឹង ភ្លេច១ភាគ៤ ក្នុងរយៈពេល៦ម៉ោង ហើយក្នុង២៤ ម៉ោង យើងនឹងភ្លេច១ភាគ៣ ហើយយើងនឹងភ្លេចអស់៩០ភាគរយ ក្នុងរយៈពេល៦សប្តាហ៍ "។ កម្មវិធីនេះ បានបញ្ចប់ប្រកបដោយអត្ថន័យដ៏ជ្រាលជ្រៅជាទីបំផុតក្នុងដួងចិត្តរបស់សិស្សានុសិស្សម្នាក់ៗ។ ឆ្លៀតឱកាសនោះដែរយើងបានជួបសំណេះសំណាលជាមួយយុវសិស្ស សែម សំ អាង ជាសិស្សពូកែទទួលជ័យលាភី ចំណាត់ថ្នាក់លេខ១ ទូទាំងប្រទេស ប្អូនបានរៀបរាប់ថា មកដល់ឆ្នាំនេះប្អូនមានអាយុ ១៩ ឆ្នាំហើយរៀននៅថ្នាក់ទី ១២ **A** មានឪពុកម្តាយជាកសិករ ទីលំនៅភូមិអំពិល ឃុំកំបូល ស្រុកអង្គស្នួល ខេត្តកណ្តាល ។ មានបងប្អូន ៦ នាក់ រូបប្អូនជាកូនទី ៥ក្នុងគ្រួសារ

ជារៀងរាល់ថ្ងៃការធ្វើដំណើរមកវិទ្យាល័យពេលព្រឹកប្អូនជិះកង់មករៀនរហូតដល់ម៉ោង ១១ ក្រោយពីស្រស់ស្រូបអាហារថ្ងៃត្រង់នៅសាលាមកប្អូនត្រូវនៅរៀនរហូតដល់ម៉ោង ២រសៀល ទើបត្រឡប់ទៅផ្ទះវិញ ។ ប្អូនបានបញ្ជាក់ផងដែរថា ជារៀងរាល់ម៉ោងទំនេរ ប្អូនតែងតែចូលបណ្ណាល័យរកសៀវភៅទាក់ទិននិងមេរៀនមកអាននិងកត់ត្រាបន្ថែមមិនដែលខានឡើយ ។ប្អូនយកបណ្ណាល័យនេះជាកន្លែងស្រាវជ្រាវមួយ ដើម្បីជំរុញអោយប្អូនក្រេបយកចំណេះដឹង បង្កើនសមត្ថភាពអោយបានរីកចំរើនជាលំដាប់។ ប្អូនបានបន្តទៀតថា នៅថ្ងៃទី៥ឧសភា ២០០៦ ក្រោយពីបានជោគជ័យនៅចំណាត់ថ្នាក់ខេត្តរួចមកប្អូនត្រូវចូលរួមប្រឡងនៅថ្នាក់ទូទាំងប្រទេសទៀតចំនួន៣ថ្ងៃដែលឆ្នាំនេះក្រសួងបានរៀបចំនៅទីក្រុងសៀមរាប ខេត្តសៀមរាម។ នេះក៏ជាសំណាងលើកទីមួយរបស់ប្អូនដែរដែលបានធ្វើដំណើរកំសាន្តទស្សនាប្រាសាទអង្គរដ៏ល្បីល្បាញរបស់ប្រទេសកម្ពុជាយើង ក្រោយកម្មវិធីប្រឡងបានចប់រួចរាល់មក។ ថ្ងៃទី១១ ឧសភា ជាថ្ងៃប្រកាសលទ្ធផលប្រឡងនិងជាថ្ងៃដែលប្អូននិង សិស្សានុសិស្សជាបេក្ខជនប្រឡងដទៃទៀតទន្ទឹងរង់ចាំយ៉ាងអន្ទះសា។

---

# សុខលីម អាយុ ៣៨ឆ្នាំ...

ថ្ងៃទី៦ខែធ្នូឆ្នាំ២០០១ ខ្ញុំត្រូវបានកាត់រំសាយជាស្ថាពរពីជួរកងទ័ពដោយទទួលបានប្រាក់ឧបត្ថម្ភផ្តាច់ចំនួន ១,៦០០,០០០រៀល ( មួយលានប្រាំមួយសែនរៀល) ។

ពេលនោះខ្ញុំគិតថាខ្លួនខ្ញុំពិការទៅហើយមិនអាចបំរើជាតិធ្វើជាកងទ័ពដូចពីមុនបានទៀតទេ ដូចនេះវាជាការ ល្អម្យ៉ាងដែរដែលខ្ញុំអាច វិលមករួមរស់ជាមួយប្រពន្ធកូនរបស់ខ្ញុំវិញ ។

ថ្ងៃមួយបុគ្គលិកអង្គការមេត្តាករុណាបានចុះមកធ្វើការនៅក្នុងភូមិខ្ញុំដើម្បីជួយផ្តល់រទេះដល់ជនពិការដែលមិនអាចធ្វើដំណើរបានដោយខ្លួនឯងនិងចុះស្រាវជ្រាវរកអ្នកពិការដែលចង់ទៅរៀនវិជ្ជាជីវៈនៅមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈបន្ទាយព្រាបរបស់អង្គការ **JS** ។

ពេលនោះខ្ញុំត្រេកអរជាខ្លាំង ខ្ញុំក៏សំរេចចិត្តចុះឈ្មោះទៅរៀនដោយជ្រើសរើសជំនាញជាងឈើព្រោះខ្ញុំបានចេះផ្នែកជាងឈើនោះខ្លះៗដែរហើយស្រុកខ្ញុំសំបូរឈើមានតំលៃថោកដែលអាចធ្វើ តុ ទូលក់បានក្នុងភូមិមិនបាច់ទៅឆ្ងាយពីផ្ទះ"។ ក្រោយពីចប់វគ្គសិក្សាមួយឆ្នាំក្រោយមកអង្គការមេត្តាករុណាបានផ្តល់ដើមទុនអោយខ្ញុំខ្ចីទិញសំភារៈនិងឈើខ្លះដើម្បីប្រកបមុខរបរជាជាងធ្វើតុទូនិងជួយប្រពន្ធខ្ញុំអោយលក់ចាប់ហួយនិងចិញ្ចឹមជ្រូករួមផ្សំក្នុងជីវភាពប្រចាំថ្ងៃ។ ក្នុងមួយខែគាត់អាចធ្វើទូបានពី២ទៅ៤ លក់ក្នុងទូមួយតំលៃ ១៨០,០០០ រៀលដោយចំណាយដើមអស់១០៥,០០០រៀលបច្ចុប្បន្ននេះអាចរកផលចំណូលបានពី១៤,០០០ រៀល ទៅ ១៥,០០០រៀល ក្នុងមួយថ្ងៃ ។

" ទន្ទឹមនិង នោះខ្ញុំមានដីស្រែចំនួន



*ទៅអនាគតខ្ញុំមានគំរោងសន្សំប្រាក់ទិញម*
*កំលាំងនិងងាយស្រួលបន្តិចព្រោះឈូស*
*អោយ*

ខណៈនោះនៅពេលលោកប្រធានគណៈកម្មការប្រឡងប្រកាសថាប្អូនត្រូវទទួលជ័យលាភីជាប់ចំណាត់ថ្នាក់លេខ១មុខវិជ្ជាអក្សរសាស្ត្រខ្មែរ ភ្លាមប្អូនមានអារម្មណ៏រំភើបរីករាយយ៉ាងខ្លាំងដែលប្អូនយល់ថានេះជាភ័ព្វសំណាងធំណាស់ព្រោះក្នុងមួយជីវិតនេះប្អូនមិនដែលបានជួបព្រឹត្តការណ៏ដូចពេលនេះទេជាពិសេសឪពុកប្អូនដែលអមដំណើរជាមួយគាត់ក៏មានអារម្មណ៏សប្បាយញញឹមពព្រាយរីករាយឥតឧបមា។ ជាកិត្តិយសប្អូនត្រូវបានទទួលនូវមេដាយមាស វិញ្ញាបនប័ត្រនិងសេចក្តីប្រកាសចេញដោយក្រសួងអប់រំយុវជន និង កីឡា ភ្ជាប់និងទឹកប្រាក់៨០មុឺនរៀលផង។ ថ្ងៃកំណត់បានមកដល់ប្អូនបានវិលត្រឡប់មកពីភូមិកំណើតវិញដោយពាំនាំមកជាមួយនូវមោទនភាពដ៏ធំធេងភាពជឿជាក់និងអំណរសប្បាយ។ ជោគជ័យនៃការព្យាយាមរបស់ប្អូននៅពេលនេះបានកើតចេញជារូបរាងហើយ។ ប្អូនបានរៀបរាប់ជាបន្តនូវបទពិសោធន៏មួយចំនួនស្តីពីគំនិតរបស់ប្អូនផ្ទាល់អោយយើងដឹងថាការរៀនអោយពូកែគឺជាបំណងប្រាថ្នារបស់អ្នកសិក្សាទាំងឡាយ។ ប៉ុន្តែដើម្បីសំរេចបំណងនេះក៏ត្រូវមានកត្តាជាច្រើនរួមផ្សំ ផងដែរ ។ **កត្តា**ទាំងនោះរួមមាន **: ១-គ្រួសារ** ជួយទំនុកបំរុងនិងលើកទឹកចិត្តគ្រប់បែបយ៉ាង។ **២-សង្គមបរិយាកាស ខាងក្រៅ** គឺអ្នកនៅក្នុងភូមិស្រុកជាមួយដូចជាចាស់ព្រឹទ្ធាចារ្យអ្នកមានចំណេះដឹងឬអ្នកដទៃដែលបានជួយផ្តល់ជាគំនិតយោបល់ និងបទពិសោធន៏ល្អសំរាប់ពួកយើង។ **៣-សាលារៀន** មានលោកគ្រូអ្នកគ្រូខិតខំបង្ហាត់បង្រៀនសិស្សនិងជាអ្នកតំរែតំរង់ទិសអោយយើង។ **៤-មិត្តភក្តិ**មានការជ្រោមជ្រែងផ្តល់ជាឯកសារសៀវភៅសិក្សាមិត្តមួយចំនួនជាអ្នកផ្តល់យោបល់ប្រឹក្សា ផ្តល់ជាចំនេះដឹងល្អៗ និងដំបូន្មានគួរយកតំរាប់តាម ។ **៥- ខ្លួនឯងផ្ទាល់** ត្រូវព្យាយាមរៀនសូត្រ ស្តាប់គ្រូឪពុកម្តាយ ស្វះស្វែងរកឯកសារមកស្រាវជ្រាវអោយបានច្រើនដែលមាននៅក្នុងបណ្ណាល័យ ឧស្សាហ៏អានសៀវភៅនានាដែលពាក់ពន្ធ័និងការរៀនសូត្រ។ បទពិសោធន៏ទាំង៥ដែលបានសំអាងខាងលើនេះជាចំណុចសំខាន់សំរាប់ជាប្រយោជន៏អោយប្អូនៗអ្នកសិក្សាជំនាន់ក្រោយធ្វើជាមតិគំនិតពិចារណាបន្ថែម។ សូមអោយការព្យាយាមរៀនសូត្ររបស់ប្អូនៗទទួលបានផលផ្លែល្អដើម្បីក្លាយខ្លួនជាសិស្សពូកែដោយយកប្អូនជាសិស្សគំរូម្នាក់ឈានទៅរកភាពជោគជ័យនៃជីវិត។ **ជោគជ័យនៃជីវិតស្ថិតលើការព្យាយាមនិងជឿជាក់** ។៚

*ឡុង សុផល JS: បន្ទាយព្រាប*



គតខ្ញុំមានគំរោងសន្សំប្រាក់ទិញម៉ាស៊ីន ច្រៀកឈើឈូសឈើធុនកណ្តាលមួយដើម្បីអោយធូរ និងងាយស្រួលបន្តិចព្រោះឈូសឈើរនឹងដៃមិនសូវបានលឿននិងឆ្លើយតបតំរូវការអតិថិជន អោយបានទាន់ពេលវេលាឡើយ។

១៧ រ៉ៃ(២,៧២ហិចតា)ដែលទទួលផលស្រូវបានពី៥០ទៅ៥៥បាវក្នុងមួយឆ្នាំដែរ។ ទៅអនាគតខ្ញុំមានគំរោងសន្សំប្រាក់ទិញម៉ាស៊ីនច្រៀកឈើឈូសឈើធុនកណ្តាលមួយ ដើម្បីអោយធូរកំលាំងនិងងាយស្រួលបន្តិចព្រោះឈូសឈើនឹងដៃមិនសូវបានលឿននិងឆ្លើយតបតំរូវការអតិថិជនអោយបានទាន់ពេលវេលាឡើយ ។

ខ្ញុំសូមផ្តាំផ្ញើដល់បងប្អូនពិការទាំងអស់ថាត្រូវចេះតស៊ូក្នុងជីវិតរបស់យើងម្នាក់ៗ។ត្រូវរកអាជីពអ្វីមួយដែលពិតប្រាកដសំរាប់ខ្លួនយើង កុំចំណាយពេលវេលាដោយឥតប្រយោជន៏អោយសោះដូចពាក្យចាស់លោកពោលថា" រពឹសដៃផ្ទៃឆ្អែត" ដោយប្រព្រឹត្តតែអំពើសុចរិតទើបជាមនុស្សថ្លៃថ្នូរព្រោះខ្ញុំសង្កេតឃើញថាបងប្អូនពិការខ្លះបានចំណាយពេលឥតប្រយោជន៏សុំទានបានលុយយកទៅផឹកស្រា លេងបៀធ្វើអោយជីវិតគ្រួសារជួបតែភាពអាប់អួរ។ សូមគិតថា យើងពិការតែ-អវយវៈទេតែចិត្តរបស់យើងមិនពិការទេ ។ ត្រូវចេះតស៊ូដើម្បីអនាគតក្រុមគ្រួសារ របស់យើងទៅថ្ងៃខាងមុខទៀត ។"

"ចំពោះរូបនាងខ្ញុំជាប្រពន្ធក៏សូមផ្តាំផ្ញើដល់ស្ត្រីឯទៀតដែលមានប្តីជាជនពិការដូច រូបខ្ញុំត្រូវចេះអត់ធ្មត់ជួយលើកទឹកចិត្តអោយចេះប្រឹងប្រែងរកស៊ីរួមគ្នាដើម្បីសុភមង្គលជីវិតអនាគតក្នុងគ្រួសារ ។៚

*ដោយ សុខ អេង - JS: បន្ទាយមានជ័យ*

N"07_A4_5.qxd 06/16/2006 10:19 Morning Page VIII

# តើកុមារអាចចូលរួមបំបាត់អំពើហិង្សាបានដែរឬទេ???

## កុមារអាចជួយយើងបានពេល មានអំពើហិង្សាក្នុងគ្រួសារ !






បងត្រូវគិតថាកូនរបស់បងអាចជួយបងបាន



កូនអាណិតម៉ាក់ណាស់ .........។



មានរឿងអីហ្នឹង........

## ផ្នែកព័ត៌មាន និង និពន្ធ

នឿន តុងលាង ( Tin Tin )
សុខ អេង
សូ ណុត

## កែអត្ថបទ

លោក នី ញ៉ លោក ឡុង សុផល
លោក ជឹម សាវ៉ន កញ្ញា កុល សៀប
កញ្ញា បញ្ញកា លោក ឃួន សំអែល


ព្រាបសន្តិភាព

ផ្ទះលេខ: ៩៦ ផ្លូវ ៩៩២
បឹងកកពីរ ទួលគោក ភ្នំពេញ
ទូរសព្ទលេខ: ០២៣ ៨៨០ ១៣៩
០២៣ ៨៨០ ៤៥៥
ប្រអប់សំបុត្រ:
P.O.Box: 880 Phnom Penh
អ៊ីមែល: jrscam@forum.org.kh
គេហទំព័រ: www.jrscambodia.org